# 01. ពេលអ្នកមានមេរោគហេចអាយវី

1.1 តើឥឡូវមានអ្វីកើតឡើង។
1.2 ការរក្សារភាពសំងាត់និងការើសអើង
1.3 តើខ្ញុំប្រាប់នរណា?
1.4 តើមានអ្វីកើតឡើងប្រសិនបើជាខ្ញុំមិនមែនជាអ្នករស់នៅអចិន្ត្រៃក្នុងប្រទេសអូស្ត្រាលីទេ?

## 1.1 តើឥឡូវមានអ្វីកើតឡើង។

វាអាចជាការមួយដ៏លំបាក នៅពេលដែលអ្នកដឹងថា ក្នុងខ្លួនអ្នកមានមេរោគ HIV។ មាន មនុស្សជាច្រើនដែលនៅតែពុំទាន់ដឹងអំពីមេរោគ HIV ឬជម្ងឺ AIDS ហើយគួរឱ្យស្តាយ ព្រោះមានជំនឿដែលមិនពិតអំពីជម្ងឺនេះ។ ទោះជាអ្នកមានកើតមេរោគ HIV ជាយូរមក ហើយក៏ដោយ អ្នកប្រហែលជាមានអារម្មណ៍ច្របូកច្របល់ ហើយព្រួយបារម្ភអំពីអនាគត។ អ្នកអាចមានអារម្មណ៍ថា ជម្ងឺនេះកើតទៅលើអ្នកតែប៉ុណ្ណោះ។

គឺជាការសំខាន់ដែលអ្នកត្រូវចាំថា វាមិនកើតតែចំពោះអ្នកប៉ុណ្ណោះទេ។ មានប្រជាពលរដ្ឋ រាប់ពាន់នាក់ ក្នុងប្រទេសអូស្ត្រាលី ដែលកំពុងតែរស់នៅដោយមានមេរោគ HIV ឬជម្ងឺ AIDS រួមបញ្ចូលទាំងមនុស្សជាច្រើនទៀត មកពីប្រភពសាវតានានា។

ការរៀនរស់នៅជាមួយមេរោគ HIV ឬជម្ងឺ AIDS អាចប្រើពេលវេលាយូរ ហើយអ្នកដែល <u>មានមេរោគហេចអាយវី-ហេចអាយវីវិជ្ជមាន (HIV Positive)</u> ត្រូវផ្លាស់ប្តូរនូវរបៀបដែល គេរស់នៅ ធ្វើការងារ និងទំនាក់ទំនងរវាងដៃគូ ក្រុមគ្រួសារ និងមិត្តភ័ក្រ្ត។ អ្នកអាច លៃលកតាមសម្រួល នូវពេលវេលាឱ្យងាយស្រួលសំរាប់អ្នក ក្នុងការធ្វើការសំរេចចិត្តទៅ អនាគត ដោយមិនចាំបាច់ ធ្វើការសំរេចចិត្តភ្លាម១តែម្តងនោះទេ។

មានអង្គការជាច្រើនក្នុងប្រទេសអូស្ត្រាលី ដែលអាចជួយអ្នកដោយផ្តល់ពត៏មាន ឱវាទ និងជំនួយ។ បុគ្គលិកជាច្រើនដែល ធ្វើការនៅក្នុងអង្គការទាំងនេះ ក៏មានមេរោគ HIV ដែរ ហើយអង្គការខ្លះទៀត ដូចជាអង្គការមនុស្សរស់នៅជាមួយមេរោគ HIV ឬជម្ងឺ AIDS (PLWHA) គឺសំរាប់អ្នកមាន មេរោគ HIV ក្រុមគ្រួសារ ដៃគូ និងមិត្រភក្តិរបស់គេ។ ☎

ក្រុមគ្រួសារខ្ញុំមកនៅទីនេះ នៅពេលដែលខ្ញុំនៅតូច ដូច្នេះខ្ញុំនិយាយដូចអូស្ត្រាលីហើយខ្ញុំ មានអារម្មថាខ្ញុំជាជនជាតិអូស្ត្រាលី។ ក៏ប៉ុន្តែទំនៀមទំលាប់ និងជំនឿរបស់ឪពុកម្តាយខ្ញុំ ខុសពីខ្ញុំ។ ខ្ញុំពុំអាចប្រាប់គាត់ថា ខ្ញុំជាមនុស្សដែលស្រឡាញ់មនុស្សមានភេទដូចគ្នា ឬមួយក៏ ជាមនុស្សមានមេរោគ HIV នោះទេ ពួកគាត់នឹងពុំអាចទ្រាំទ្របានឡើយ។ វាគឺជាការ ពិបាកចំពោះខ្ញុំ ព្រោះមិត្រភក្តិខ្ញុំ និងបុគ្គលិកធ្វើការថែរក្សាសុខភាពខ្លះមិនយល់អំពីទុក្ខ ធុរៈខ្ញុំ។ ទីបំផុតខ្ញុំបានរកឃើញនូវ ការគាំទ្រអំពីសេវាកម្ម ដែលមានអតិថិជនច្រើន ដែលមានដើមកំណើតផ្សេង១ ហើយបុគ្គលិកធ្វើការទាំងនោះ យល់អំពីទំនាស់រវាង ទំនៀមទំលាប់ ដែលខ្ញុំរស់នៅ ហើយជួយដោះស្រាយពីបញ្ហានោះ។

## 1.2 ការរក្សារភាពសំងាត់និងការើសអើង

<u>ការរក្សាភាពសម្ងាត់ (Confidentiality)</u> គឺមានន័យថា ពត៏មានអ្វីដែលមន្ទីរសុខភាព ឬក្រុម ផ្នែក HIV / AIDS ដឹងអំពីអ្នក គឺជារឿងឯកជនហើយពួកគេពុំអាចផ្តល់ពត៏មាននេះ ដល់អ្នក ណាផ្សេងទៀតបានឡើយ លុះត្រាតែមានការអនុញ្ញាត ពីអ្នក។

ក្នុងប្រទេសអូស្ត្រាលី វាគឺជាការខុសច្បាប់ ពេលដែលបុគ្គលិកធ្វើការក្រសួងទាំងនោះ ពិភាក្សាអំពីរឿងថែទាំសុខភាពរបស់អ្នក ឬសូម្បីតែនិយាយប្រាប់អ្នកដទៃ ថាអ្នកបានប្រើ នូវសេវាកម្មក្រសួងនោះក៏ដោយ លុះត្រាតែមានការអនុញ្ញាត អំពីអ្នក។

ច្បាប់ទាំងនេះមិនមែនតែចំពោះវេជ្ជបណ្ឌិតនិងគិលានុបដ្ឋាយិកានោះទេ វាក៏ប្រើចំពោះ បុគ្គលិកសង្គមកិច្ច (Social Worker) អ្នកផ្តល់យោបល់និងឱវាទ (Counselllor) អ្នកបកប្រែ (Interpreter) ហើយនិងលេខាធិការផងដែរ។ អ្នកទាំងអស់នេះ មិនអាចប្រាប់ដល់ ប្តី ប្រពន្ធ ដៃគូ ឪពុកម្តាយ ឬកូនរបស់អ្នកអំពីសុខភាពអ្នក ដោយគ្មានការអនុញ្ញាតពីអ្នកឡើយ។

ពេលខ្លះអ្នកប្រហែលជាមានអារម្មណ៍ថា មានមនុស្សជាច្រើនដឹងនូវរឿងផ្ទាល់ខ្លួនរបស់ អ្នក។ ឧទាហរណ៍ នៅទីកន្លែងព្យាបាលជម្ងឺ អ្នកឃើញមានវេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា និង បុគ្គលិកផ្សេងៗទៀតជាច្រើន។ នេះមកពីបុគ្គលិកនៅក្នុងកន្លែងពិនិត្យ ព្យាបាលរោគ និង មន្ទីរពេទ្យធ្វើការរួមគ្នាជាក្រុម។ ចំណេះវិជ្ជាអ្វី ឬក៏ការពិភាក្សាអ្វី ដែលពួកគេធ្វើ ហើយទាក់ទងទៅនឹងស្ថានការណ៍មេរោគ HIV (HIV Status) របស់អ្នក គឺក្នុងគោលបំណង ផ្តល់ដល់អ្នកនូវការថែរក្សាដ៏ល្អមួយចំពោះអ្នក។

ការរើសអើង

ការរើសអើង (Discrimination) គឺជាអំពើមិនសមរម្យចំពោះមនុស្សម្នាក់ ឬក៏ទៅលើ មនុស្សមួយក្រុម ពីព្រោះតែភេទ ការរួមភេទ ពូជសាសន៍ ពណ៌សម្បុរ បញ្ហាសុខភាព ឬក៏ ជំនឿសាសនា។ នៅក្នុងប្រទេសអូស្ត្រាលីវាគឺជាការខុសច្បាប់ ចំពោះ បុគ្គលិកផ្នែកសុខ ភាពណាដែលរើសអើងទៅលើអ្នក ធ្វើការវិនិច្ឆ័យទៅលើអ្នក ផ្តន្ទាទោសអ្នក ឬមួយក៏ បដិសេធនូវសេវាកម្មដោយសារតែ:

- អ្នកមានមេរោគ HIV
- អ្នកមិនចេះនិយាយភាសាអង់គ្លេស ឬក៏និយាយភាសាអង់គ្លេសមិនសូវច្បាស់
- អ្នកមិនមែនជាសញ្ជាតិអូស្ត្រាលី
- ឋានៈ អាពាហ៍ ពិពាហ៍ របស់អ្នក
- អ្នកមានពិការភាព
- អ្នកជាបុរស
- អ្នកជាស្ត្រី
- អ្នកជាស្រីដែលរួមភេទជាមួយស្ត្រី ឬប្រុសដែលរួមភេទជាមួយបុរស ឬអ្នក ដែលរួមភេទជាមួយទាំងបុរស ហើយស្ត្រី ឬក៏អ្នកផ្លាស់ប្តូរភេទ (Transgender)
- អ្នកជាបុរសដែលរួមភេទជាមួយស្ត្រី ឬក៏ស្ត្រីដែលរួមភេទជាមួយបុរស ឬអ្នក កំពុងប្រើថ្នាំញៀន។

បើសិនជាអ្នកមានអារម្មណ៍ថា អ្នកត្រូវបានគេរើសអើង ឬចាត់ទុកថា

មិនស្មើភាពនូវប្រការ ទាំងនេះ ឬបញ្ហាណាផ្សេងទៀត អ្នកអាចដាក់ពាក្យប្តឹងតវ៉ា។ នៅផ្នែកខាងក្រោយនៃ សៀវ ភៅនេះមានលេខទូរស័ព្ទទាក់ទង Anti-discrimination Board/Commission ក្នុងរដ្ឋនីមួយៗ និងដែនដី។ បុគ្គលិកធ្វើការនៅផ្នែកទាំងនេះនឹងជំរាបអ្នក បើសិនជាអ្នក មានលក្ខណ: គ្រប់គ្រាន់ដើម្បីដាក់ពាក្យតវ៉ា។ ការប្តឹងតវ៉ាមិនមែនបានន័យថា អ្នកបង្កើតឱ្យមានបញ្ហាទេ។ មនុស្សគ្រប់រូប មានសិទ្ធិប្រើសេវាកម្មត្រឹមត្រូវ និងដោយ ក្តីគោរព។ ☎

## 1.3 តើខ្ញុំប្រាប់នរណា?

ជាទូទៅ នេះជាសំណួរពិបាកមួយ ។ ខ្លួនអ្នកមានមេរោគ HIV មិនមែនអ្វីដែលត្រូវខ្មាស់ អៀនទេ។ យ៉ាងណាមិញ វាមានពាក្យមិនពិត ដែលគេតែងតែជឿនូវពត៌មានខុស នៅក្នុង សហគមន៍ជាទូទៅហើយមនុស្សដែលមានមេរោគ HIV គួរតែគិតឱ្យបានច្បាស់លាស់ថា តើនរណាដែលគួរឱ្យ ទុកចិត្តនឹងនិយាយប្រាប់។

ច្បាប់ទម្លាប់ជាទូទៅគឺត្រូវនិយាយប្រាប់ជនដែលត្រូវដឹង អ្នកទាំងនោះអាចរួមបញ្ចូលទាំង:

- វេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា ពេទ្យធ្មេញ អ្នកឱ្យឱវាទ ហើយនិងមនុស្សដទៃទៀត ដែលផ្តល់ដល់អ្នក នូវការថែរក្សាទាក់ទងនឹងមេរោគ HIV ឬ AIDS។
- អ្នកណាដែលជាដៃគូរួមសង្វាសជាមួយអ្នក។ ជាការសំខាន់ដែលអ្នកប្រាប់មនុស្សដែលអ្នកទុកចិត្ត និងមនុស្សដែលជួយគាំទ្រអ្នក ចំណាយ ពេលវេលានឹងអ្នកទាំងនោះ អាចធ្វើឱ្យលោកអ្នកដឹងបានថា តើមនុស្សទាំងនោះ ជាមនុស្សរបៀបណា។ ក្នុងកាលៈទេសៈច្រើនដែលលោកអ្នកមិនចាំបាច់ និយាយប្រាប់ថា អ្នកមានមេរោគ HIV ដល់អ្នកដទៃដូចជា:
- ប្រធាននាយកដ្ឋានរបស់អ្នក
- អ្នកធ្វើការងាររួមគ្នា
- មនុស្សដែលរួមផ្ទះជាមួយ
- មនុស្សដែលរៀនជាមួយ ឬ
- មនុស្សដែលនិយាយជាមួយ។

មុនដំបូងនៅពេលដែលខ្ញុំដឹងថា ខ្ញុំមានមេរោគ HIV ខ្ញុំមានការភ័យខ្លាចណាស់។ ខ្ញុំពុំបានដឹងអ្វីសោះអំពីមេរោគ HIV / AIDS ខ្ញុំពុំបានដឹងអំពីសេវាកម្មណាមួយ ឬក៏កន្លែងដែលខ្ញុំអាចទៅរៀនបន្ថែមឡើយ។ ខ្ញុំបាននិយាយប្រាប់ថា ខ្ញុំមាន មេរោគ HIV ដល់មនុស្សខ្លះដែលខ្ញុំមិនគួរនឹងនិយាយប្រាប់។ ពួកទាំងនោះបាននិយាយពីរឿងខ្ញុំប្រាប់ត ដល់អ្នកដទៃទៀត ហើយមិនយូរប៉ុន្មានក៏គេដឹងគ្រប់ៗគ្នា។ ក្រុមគ្រួសារខ្ញុំបានមិននៅ ទីនោះទេ ម្លោះហើយពួកគាត់មិនបានខ្វល់នឹង រឿងនេះឡើយ។ មិត្រភក្តិដែលខ្ញុំស្គាល់ មិនរវល់ថាខ្ញុំមានមេរោគ HIV ទេ ហើយខ្ញុំបានចូលរួមនឹងក្រុមគាំទ្រមនុស្សក្មេងៗ ដែលមានមេរោគ HIV។ ខ្ញុំនៅ តែប្រាប់គេថាខ្ញុំមានមេរោគ HIV ខ្ញុំគ្រាន់តែប្រុងប្រយ័ត្នថា អ្នកណាដែលខ្ញុំត្រូវប្រាប់។

## 1.4 តើមានអ្វីកើតឡើងប្រសិនបើជាខ្ញុំមិនមែនជាអ្នករស់នៅអចិន្ត្រៃក្នុងប្រទេសអូស្ត្រាលីទេ?

មនុស្សគ្រប់រូបដែលដាក់ពាក្យសុំជ្រកកោនជាអចិន្ត្រៃយ៍នៅប្រទេសអូស្ត្រាលី ត្រូវតែឆ្លង កាត់ការពិនិត្យអង្គបដិបក្ខនៃមេរោគ HIV ហើយនិងពិនិត្យសុខភាពផ្សេងៗទៀត។ ច្បាប់ និងបទបញ្ញាទាក់ទង នឹងការឱ្យសិទ្ធិជ្រកកោនជាអចិន្ត្រៃយ៍ គឺស្មុគស្មាញពិបាកយល់ណាស់។
បើសិនជាអ្នកនឹងដាក់ពាក្យសុំសម្រាប់ការរស់នៅជាអចិន្ត្រៃយ៍ ឬក៏បានដាក់ពាក្យសុំ រួចមកហើយ គឺជាការសំខាន់ដែលអ្នកត្រូវរកឱវាទផ្នែកច្បាប់។

ចូរទាក់ទងទៅក្រុមប្រឹក្សា AIDS នៅក្នុងរដ្ឋ ឬដែនដីរបស់អ្នកឱ្យបានឆាប់រហ័ស ដែលអាច ធ្វើទៅបាន។ ក្រុមប្រឹក្សា AIDS ខ្លះមានបុគ្គលិកអាចជួយអ្នកជាមួយ និងបញ្ហាទាក់ទង ក្រសួងអន្តោប្រវេសន៍ ហើយខ្លះទៀតអាចផ្តល់ឱវាទដល់អ្នក ពីកន្លែងដ៏ល្អដើម្បីឱ្យអ្នកបាន ទទួលជំនួយ។